គោលការណ៍ជួលទីលំនៅសហគមន៍របស់រដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា នឹងរៀបចំឲ្យមានការផ្លាស់ប្តូរពីវិធីដែលថ្លៃឈ្នួលផ្ទះត្រូវបានគិតសំរាប់អ្នកជួលទីលំនៅ Community Housing ដែលមានសិទ្ធទទួលប្រាក់ជំនួយថ្លៃឈ្នួលផ្ទះសហព័ន្ធ (CRA)។

**តើគោលការណ៍បង់ថ្លៃឈ្នួលផ្ទះរបស់ Community Housing ជាអ្វី?**

នេះគឺជាគោលការណែនាំមួយចំនួន បង្កើតឡើងដោយការិយាល័យផ្គត់ផ្គង់ទីលំនៅសហគមន៍ សំរាប់ស្ថាប័នផ្គត់ផ្គង់ទីលំនៅសហគមន៍ ដើម្បីកំណត់ទៅលើចំនួនថ្លៃជួលទីលំនៅ ដែលត្រូវបង់ដោយអ្នកជួលទីលំនៅ។ Hume Community Housing Association Company Limited ត្រូវតែអនុលោមទៅតាមគោលការណ៍នេះ។

**តើប្រាក់ជំនួយថ្លៃឈ្នួលផ្ទះសហព័ន្ធជាអ្វី (CRA)?**

CRA គឺជាប្រាក់ជំនួយដើម្បីជួយដល់អស់អ្នកដែលមានប្រាក់ចំណូលតិច ដើម្បីបំពេញទៅលើតម្លៃនៃការជួលផ្ទះរបស់គេ។ ក្នុងភាពជាអ្នកជួលផ្ទះរបស់ស្ថាប័ន Community Housing លោកអ្នកមានសិទ្ធិទទួលការវាយតម្លៃដោយ Centrelink ដើម្បីទទួលយក CRA។ ប្រសិនបើលោកអ្នកមានសិទ្ធិទទួល CRA លោកអ្នកត្រូវប្រាកដឲ្យបានច្បាស់ថា លោកអ្នកទាមទារយកសិទ្ធិពេញរបស់លោកអ្នក ដោយព្រោះថាចំនួនប្រាក់នេះនឹងត្រូវគិតបញ្ចូលនៅក្នុងការគិតថ្លៃឈ្នួលផ្ទះដែលត្រូវបង់របស់លោកអ្នកទៅឲ្យ Hume Community Housing Association។

**តើថ្លៃឈ្នួលផ្ទះរបស់ខ្ញុំនឹងត្រូវបានគេវាយតម្លៃដោយបែបណា? (មិនរាប់បញ្ចូលកម្មវិធីពិសេសទាំងឡាយ)**

លោកអ្នកនឹងត្រូវបង់:

- គ្រប់ទាំងសិទ្ធិ CRA នៃអ្នករស់នៅក្នុងផ្ទះរបស់លោកអ្នកទាំងអស់ *បូកនឹង*
- លោកអ្នកនឹងត្រូវបន្តបង់ដូចបានកំណត់ក្នុងតារាងខាងក្រោមនេះ។

**កំរិតនៃប្រាក់ចំណូលដែលអាចយកមកវាយតម្លៃ (មានរួមទាំង CRA) ដែលអាចបង់នៅក្នុងថ្លៃឈ្នួលផ្ទះ**

| ប្រាក់ចំណូល | អត្រា |
|---|---|
| អ្នកកាន់កាប់កិច្ចសន្យាជួលទាំងអស់ | ២៥ភាគរយ |
| សមាជិកអ្នករស់នៅក្នុងផ្ទះឯទៀត អាយុ២១ឆ្នាំ និងលើសពីនេះ | ២៥ភាគរយ |
| សមាជិកអ្នករស់នៅក្នុងផ្ទះឯទៀត អាយុ១៨ឆ្នាំ (ដែលរាប់បញ្ចូល) រហូតដល់ទៅអាយុ២១ឆ្នាំ | ១៥ភាគរយ |
| សមាជិកអ្នករស់នៅក្នុងផ្ទះឯទៀត អាយុ១៦ឆ្នាំ ទៅ១៨ឆ្នាំ | ឥតមានទេ |
| សិស្សរៀនពេញពេល អាយុនៅក្រោម២៥ឆ្នាំ | ១៥ភាគរយ |
| ប្រាក់បំណាច់ពន្ធដារគ្រួសារ ផ្នែក A និង B | ១៥ភាគរយ |
| ប្រាក់ជំនួយថ្លៃឈ្នួលផ្ទះសហព័ន្ធ | ១00ភាគរយ |
| ទ្រព្យសម្បត្តិនៅក្រោម $5000.00 | ឥតមានទេ |
| ទ្រព្យសម្បត្តិលើសពី $5000.00 | ២៥ភាគរយនៃប្រាក់ចំណូលរកបានពីការប្រាក់ទៅតាមអត្រាចែងដោយCentrelink |

**តើការរៀបចំបង់ថ្លៃឈ្នួលផ្ទះថ្មីនេះនឹងប៉ះពាល់ដល់ខ្ញុំដោយបែបណា?**

ប្រសិនបើលោកអ្នកពុំមានសិទ្ធិទទួល CRA ទេ លោកអ្នកនឹងមិនបានប៉ះពាល់ដោយការផ្លាស់ប្តូរទាំងនេះឡើយ។ ចំពោះអស់អ្នកដែលមានសិទ្ធិ ការនេះមានន័យថាអ្នករស់នៅក្នុងផ្ទះភាគច្រើននឹងត្រូវបង់ថ្លៃឈ្នួលផ្ទះច្រើនជាង។ Hume Community Housing មានគោលការណ៍បង់ថ្លៃឈ្នួលផ្ទះអតិបរិមា។ នេះគឺដើម្បីឲ្យបានច្បាស់ប្រាកដថាក្នុងគ្រប់ទាំងករណី គ្មានអ្នកជួលផ្ទះណាម្នាក់ត្រូវបង់ច្រើនជាង៧៥ភាគរយនៃថ្លៃឈ្នួលផ្ទះតាមទីផ្សារឡើយ។

**តើការផ្លាស់ប្តូរទាំងនេះនឹងត្រូវណែនាំឲ្យមាននៅពេលណា?**

| អ្នកជួលទីលំនៅបច្ចុប្បន្ន | អ្នកជួលទីលំនៅថ្មី |
|---|---|
| ការផ្លាស់ប្តូរនឹងត្រូវអនុវត្តន៍ចាប់ពីការពិនិត្យមើលឡើងវិញលើថ្លៃឈ្នួលផ្ទះទីមួយបន្ទាប់ពីខែសីហា ឆ្នាំ២០០៨ | ការផ្លាស់ប្តូរនឹងត្រូវអនុវត្តន៍ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ |
| ថ្លៃឈ្នួលផ្ទះថ្មីនឹងចាប់អនុវត្តន៍បន្តិចម្តងៗជាលំដាប់ | ថ្លៃឈ្នួលផ្ទះថ្មីដែលកែទំរង់នឹងចាប់អនុវត្តន៍ភ្លាមៗ |
| ចំពោះអ្នករស់នៅក្នុងផ្ទះនឹងពុំមានការប៉ះពាល់ខ្លាំងដល់ការប្រមូលនៃប្រាក់ CRA របស់លោកអ្នកច្រើនជាង ១០ដុល្លា ក្នុង១ឆ្នាំឡើយ | |
| អ្នករស់នៅក្នុងផ្ទះនឹងត្រូវបង់គ្រប់សិទ្ធិ CRA របស់គេបន្ទាប់ពីរយៈពេល៤ឆ្នាំ | |

## តើការពិនិត្យមើលឡើងវិញលើថ្លៃឈ្នួលផ្ទះចាប់ផ្តើមនៅថ្ងៃណា?

Hume មានការពិនិត្យមើលឡើងវិញលើថ្លៃឈ្នួលផ្ទះចំនួនពីរដង ក្នុងមួយឆ្នាំ។ លោកអ្នកនឹងបានទទួលការផ្តល់ដំណឹងចំនួន៧២ថ្ងៃ មុនការពិនិត្យមើលឡើងវិញលើថ្លៃឈ្នួលផ្ទះនីមួយៗ។

## តើខ្ញុំត្រូវធ្វើអ្វីខ្លះ?

- ប្រសិនបើលោកអ្នកមិនទាន់បានធ្វើទេ លោកអ្នកត្រូវតែដាក់ពាក្យសំរាប់ CRA នៅ Centrelink។ ដើម្បីឲ្យបានដឹងអំពីការិយាល័យ Centrelink ដែលនៅជិតលោកអ្នកជាងគេសូមទូរស័ព្ទលេខ 132 850 ឬបើកមើលនៅត្រង់វិបសាយ www.centrelink.gov.au។

- ទាក់ទងជាមួយ Hume Community Housing ដើម្បីនិយាយអំពីការបង់ថ្លៃឈ្នួលផ្ទះរបស់លោកអ្នក តាមវិធីដែលងាយស្រួលដកចេញផ្ទាល់ពី Centrelink។

- ផ្តល់នូវគ្រប់ទាំងព័ត៌មានដែលបានស្នើសុំ នៅពេលចាប់ផ្តើមការជួលទីលំនៅរបស់លោកអ្នក ឬនៅពេលការពិនិត្យមើលឡើងវិញលើថ្លៃឈ្នួលផ្ទះរបស់លោកអ្នកបន្ទាប់ទៀត សំរាប់គ្រប់ទាំងសមាជិកដែលរស់នៅក្នុងផ្ទះ។

## តើលោកអ្នកមានសំណួរណាមួយឬទេ?

ប្រសិនបើលោកអ្នកចង់បានព័ត៌មានច្រើនថែមទៀត សូមទាក់ទង:

ក្រុមចាត់ចែងការជួលទីលំនៅ
សមាគមផ្គត់ផ្គង់ទីលំនៅសហគមន៍ Hume

Hume Community Housing Association
Level 1 119 The Crescent, Fairfield NSW 2165

ទូរស័ព្ទ: (02) 9724 0554
ទូរសារ: (02) 9728 6439

**ពេលម៉ោងធ្វើការ:**

| | | |
|---|---|---|
| ថ្ងៃច័ន្ទ | ម៉ោង៩ព្រឹក | ទៅម៉ោង៤.៣០ល្ងាច |
| ថ្ងៃអង្គារ | ម៉ោង៩ព្រឹក | ទៅម៉ោង២រសៀល |
| ថ្ងៃពុធ | ម៉ោង៩ព្រឹក | ទៅម៉ោង៤.៣០ល្ងាច |
| ថ្ងៃព្រហស្បត្តិ៍ | ម៉ោង៩ព្រឹក | ទៅម៉ោង៤.៣០ល្ងាច |
| ថ្ងៃសុក្រ | ម៉ោង៩ព្រឹក | ទៅម៉ោង៤.៣០ល្ងាច |

ឬបើកមើលនៅត្រង់វិបសាយរបស់យើង:
www.humecha.com.au

ចម្ងល់ផ្ញើតាមអ៊ីម៉ែល:
webenquiry@humecha.com.au

**ក្រុមហ៊ុនសមាគមផ្គត់ផ្គង់ទីលំនៅសហគមន៍ Hume**

**Hume Community Housing Association Company Limited**

# ថ្លៃឈ្នួលផ្ទះរបស់ COMMUNITY HOUSING សំរាប់អ្នកជួលទីលំនៅ សមាគមផ្គត់ផ្គង់ទីលំនៅ

# COMMUNITY HOUSING RENT FOR HOUSING ASSOCIATION TENANTS